# ខ្លឹមសារសង្ខេបសាលដីកាលេខ៣១៨ (២០១៨) បទដឹកជញ្ជូនសារធាតុញៀនឆ្លងដែន

## ពាក្យគន្លឹះ៖ ធាតុផ្សំបទល្មើស ធាតុផ្សំអត្តនោម័ត (ដឹង), វិមតិសង្ស័យបានជាប្រយោជន៍ ដីកាដំណោះស្រាយលុបវិការៈ មូលដ្ឋាននៃបណ្តឹងសាទុក្ខ

## ១. អង្គហេតុនិងប្រវត្តិនីតិវិធី

ក្នុងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ ជនជាតិអូស្ត្រាលីម្នាក់ ឈ្មោះនាង Taylor អាយុ ៤១ឆ្នាំ ត្រូវបានឃាត់ខ្លួនជាក់ស្តែង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដកហូតបាន Heroin ចំនួន ១២៧៧ក្រាម (ភាពសុទ្ធ៦៣ភាគរយ)។ អង្គហេតុនេះ ត្រូវបានចោទប្រកាន់ពីបទដឹកជញ្ជូនខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) តាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន។ សាលក្រមចំពោះមុខរបស់សាលាដំបូងរាជធានីភ្នំពេញ លេខ៩០កប២ ឆ្នាំ២០១៤ សម្រេចផ្តន្ទាទោស នាងជាប់គុក ២៣ឆ្នាំ និងពិន័យ៩០លានរៀល។ នាង មិនពេញចិត្តបានប្តឹងឧទ្ធរណ៍ក្នុងខែមិថុនា ឆ្នាំ២០១៤។ សាលាឧទ្ធរណ៍តាមសាលដីកាលេខ១១៨ ឆ្នាំ២០១៦ សម្រេចតម្កល់សាលក្រមលេខ៩០ ទុកជាបានការដដែល។ Taylor បានប្តឹងសាទុក្ខក្នុងខែមករា ឆ្នាំ២០១៧ ប្រឆាំងនឹងសាលាដីកាទាំងមូល។ ក្នុងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ តុលាការកំពូល បានបើកសវនាការ និងចេញសាលដីកាលេខ៣១៨ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨។

## ២. សំអាងហេតុនិងសេចក្តីសម្រេច

តុលាការកំពូលបានពិចារណា៖...៣...*ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ គ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយតាមមាត្រា២៤៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ...*។ ៤. *យល់ឃើញថាការដែលសាលាឧទ្ធរណ៍សំអាងហេតុថា ថ្នាំញៀនត្រូវបានដកហូតពី...Taylor...ហើយសន្និដ្ឋានថាមានពិរុទ្ធភាព...គឺនៅមិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា៖* ក. *តាមមាត្រា៤នៃក្រមព្រហ្មទណ្ឌ ពុំមានបទល្មើសទេ ប្រសិនគ្មានចេតនាប្រព្រឹត្ត ដូច្នេះដើម្បីកំណត់បាននូវពិរុទ្ធភាព...តុលាការ ត្រូវមានសំអាងហេតុជាក់លាក់អំពីធាតុផ្សំអត្តនោម័ត ដែលជាចេតនាទុច្ចរិតរបស់ជនជាប់ចោទ ពោលគឺនៅក្នុងរឿងនេះ សំដៅលើចេតនាដឹកជញ្ជូនសារធាតុញៀន ដែលជនជាប់ចោទបានដឹងថាជាសារធាតុញៀន ដែលច្បាប់ហាមឃាត់*។ ៨.ចំពោះសំណើសុំនេះ (ដោះលែងបណ្តោះអាសន្ន) *តុលាការកំពូលយល់ឃើញថា រឿងក្តីនេះជាបទឧក្រិដ្ឋពាក់ព័ន្ធនឹងបទល្មើសដឹកជញ្ជូនសារធាតុញៀន...ដែលការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នជាវិធានការចាំបាច់...*។

សម្រេច៖ **៣.** តម្កល់សាលដីកាលេខ១១៨ តែបដិសេធចំណុចដាក់ទោសលើ Taylor..។ **៤.** បញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ...។ **៥.** មិនព្រមដោះលែងជនជាប់ចោទឈ្មោះ Talyor...។

## ៣. កំណត់សំគាល់

១. ក្នុងរឿងនេះ មេធាវី បានលើកពីមូលដ្ឋាននៃបណ្តឹងសាទុក្ខ ដូចជាការបំពានអំណាច (ការពិនិត្យតែលើភស្តុតាងដាក់បន្ទុក) ការបំភ្លៃអង្គហេតុ តាមមាត្រា៤១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីឲ្យតុលាការកំពូលពិចារណាបណ្តឹងសាទុក្ខនេះបាន។ ក៏ប៉ុន្តែ គួរឲ្យស្តាយតុលាការកំពូល មិនបានបំភ្លឺទេ ក្រៅពីទទួលយកនូវបណ្តឹងសាទុក្ខនេះ មកពិនិត្យបាន។

២. មេធាវីបានលើកអំពីវិការៈនៃនីតិវិធី ដូចជាការឃាត់ខ្លួនគ្មានដីកា ខុសម៉ោងអនុញ្ញាត។ តុលាការកំពូលបានអះអាងថា អាជ្ញាធរមិនបានប្រព្រឹត្តខុសទេ តាមឯកសារភស្តុតាង ដោយសារវាជាបទល្មើសជាក់ស្តែង។ តុលាការកំពូល បានបន្ទយ ដោយយោងដល់មាត្រា២៩៦ ដែលយោងខាងលើ។ ខ្លឹមសារនៃសាលដីកានេះ មិនបានបង្ហាញថា មេធាវី ក្នុងនីតិវិធីមុនអង្គសេចក្តីនៅមុខសាលាដំបូង បានស្នើសុំមោឃភាពឬយ៉ាងណាទេ? អ្វីជាមេរៀន សម្រាប់មេធាវីគឺថា ត្រូវព្យាយាមសុំមោឃៈជាមុន ប្រសិនបើមិនដូចនេះទេ (ថ្លស់សិទ្ធិ) វិការៈនឹងត្រូវបានលុបបំបាត់ដោយការចេញដីកាដំណោះស្រាយ។

៣. ក្រៅពីការលើកឡើងថាតុលាការជាន់ទាប មិនបានពិចារណានូវគ្រប់ភស្តុតាង រួមទាំងភស្តុតាងដោះបន្ទុក បញ្ហាធាតុផ្សំអត្តនោម័តនៃបទល្មើស ជារឿងមួយសំខាន់ក្នុងសំណុំរឿងនេះ។ ខ្លឹមសារដកស្រង់ខាងលើ បានតម្រូវថា ត្រូវតែមានសំអាងហេតុឲ្យច្បាស់និងគ្រប់គ្រាន់អំពីធាតុផ្សំនៃបទល្មើស ប្រសិនមិនដូចនេះទេ វាអាចនឹងជាមូលហេតុនៃការប្តឹងសាទុក្ខ និងបដិសេធសាលដីកាដោយតុលាការកំពូល។ សំអាងហេតុត្រូវតែមានតាមមាត្រា៤៩៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ (មាត្រា១៤.៥) ហើយក៏ត្រូវគ្រប់គ្រាន់ បើពុំនោះទេ មានន័យថាគ្មានសំអាងហេតុ (សាលដីកាតុលាការកំពូលលេខ២៩៦(២០១៣)ទំ.៧)។

៤. អង្គហេតុកើតក្នុងឆ្នាំ២០១៣ មកដល់ថ្ងៃនៃសាលដីកាលេខ៣១៨ មានរយៈពេលប្រហែល៦ឆ្នាំ។ Taylor ត្រូវបានគេអះអាងថា ជាជនរងគ្រោះនៃអំពើល្បិចបោកជាក្រុម ដោយផ្តល់ការងារ ធ្វើឲ្យនាងទុកចិត្ត ព្រមទទួលកាបូប ដែលនាងអះអាងថា អាចជាវត្ថុចម្លាក់យកទៅលក់នៅអូស្ត្រាលី (កន្លងមកនាងធ្លាប់ដឹកដែរហើយជាចម្លាក់មែន)។ យើងមិនដឹងថា រឿងនេះពិត១០០ ភាគរយឬយ៉ាងណាទេ។ សូមរង់ចាំនូវ សូមមើលសាលដីការបស់សាលាឧទ្ធរណ៍កាត់ជាថ្មីលេខ២៧៤។ ក្នុងករណីសម្រេចឲ្យរួចផុតពីការចោទប្រកាន់ តើTaylor អាចទារសំណងបានទេ ចំពោះការកាត់សេចក្តីខុស ហើយតើនរណាជាអ្នកទទួលខុសត្រូវ? Talyor បានជាប់ពន្ធនាគារចំនួនប្រហែល៦ឆ្នាំហើយ។ នេះជាមេរៀនមួយ ដែលអ្នកត្រូវប្រយ័ត្នអំពីកលល្បិចមនុស្សមួយចំនួន ដែលអាចនាំទុក្ខទោសដល់យើងដោយមិនដឹងខ្លួន។